# សភាអឺរ៉ុប ទទូចឱ្យបន្ថែមទណ្ឌកម្មឱ្យកាន់តែធ្ងន់ធ្ងរ លើបេឡារុស



ទីស្នាក់ការកណ្តាលសភាអឺរ៉ុបនៅក្នុងទីក្រុងស្ត្រាសបួរ ប្រទេសបារាំង

ថ្ងៃសុក្រ ១១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣

កាលពីថ្ងៃពុធ ទី១៥ ខែមីនា ឆ្នាំ២០២៣ សភាអឺរ៉ុបបានទទូចឱ្យបណ្តាប្រទេសជាសមាជិកសហភាពអឺរ៉ុប ដាក់ចេញនូវទណ្ឌកម្មថ្មីលើសាធារណរដ្ឋបេឡារុស ពាក់ព័ន្ធនឹងការបង្ក្រាបលើគណបក្សប្រឆាំង និងបានគាំទ្រសង្គ្រាមរបស់សហព័ន្ធរុស្ស៊ី នៅក្នុងប្រទេសអ៊ុយក្រែន។

កន្លងមកសហភាពអឺរ៉ុបដែលមានសមាជិក២៧ប្រទេស បានវាយប្រហាររដ្ឋាភិបាលទីក្រុងមីនស្ក៍ តាមរយៈការដាក់ទណ្ឌកម្មជាច្រើនជុំរួចមកហើយ ពាក់ព័ន្ធនឹងការបង្ក្រាបផ្ទៃក្នុងរបស់ខ្លួន និងការដើរតួនាទីធ្វើជាឈ្នាន់សម្រាប់ការឈ្លានពានរបស់រដ្ឋាភិបាលទីក្រុងមូស្គូ ចូលទីក្រុងកៀវ។ សមាជិកសភាអឺរ៉ុបបានអនុម័តសេចក្តីសម្រេចមួយអំពាវនាវឱ្យសហភាពអឺរ៉ុបពង្រីកបញ្ជីជនទាំងឡាយណា ដែលពាក់ព័ន្ធនឹងការបង្ក្រាបយ៉ាងហិង្សា នៅក្នុងការបោះឆ្នោតមួយដែលបានធ្វើឡើង បន្ទាប់ពីការផ្តន្ទាទោសលោក Ales Bialiatski សកម្មជនជ័យលាភីពានរង្វាន់ណូបែល ឱ្យជាប់ពន្ធនាគាររយៈពេល ១០ឆ្នាំ។

"ចៅក្រម រដ្ឋអាជ្ញា ភ្នាក់ងារអនុវត្តន៍ច្បាប់ មន្ត្រីពន្ធនាគារ និងមន្ត្រីពន្ធនាគារដាក់អ្នកទោសនិរទេសទៅតំបន់ដាច់ស្រយាល ( penal colony ) ជាច្រើនរូបថែមទៀត គួរតែត្រូវបានដាក់បញ្ចូលក្នុងបញ្ជីខ្មៅបង្កកទ្រព្យសម្បត្តិ និងហាមឃាត់ទិដ្ឋាការ"។ ស្ថាប័ននីតិប្បញ្ញត្តិរបស់សហភាពអឺរ៉ុបមួយនេះ ក៏បានទទូចផងដែរឱ្យសហភាពអឺរ៉ុបបន្ថែមទណ្ឌកម្មកាន់តែធ្ងន់ធ្ងរថែមទៀតលើបេឡារុស ពាក់ព័ន្ធនឹងតួនាទីនៅក្នុងសង្គ្រាមនៅអ៊ុយក្រែន ដែលជាប្រទេសជិតខាងរបស់ខ្លួន ដើម្បីឆ្លុះបញ្ចាំងពីឥទ្ធិពលដ៏ខ្លាំងក្លានៃការដាក់ទណ្ឌកម្មលើរុស្ស៊ី និងទប់ស្កាត់លទ្ធភាពរបស់ទីក្រុងម៉ូស្គូក្នុងការគេចវេសពីវិធានការទាំងនេះ។

មន្ត្រីសហភាពអឺរ៉ុបរំពឹងថា នឹងរឹតបន្តឹងការដាក់ទណ្ឌកម្មលើបេឡារុសក្នុងខែកុម្ភៈកន្លងមក ប៉ុន្តែត្រូវបានជាប់គាំងដោយសារការខ្វែងគំនិតគ្នាពាក់ព័ន្ធនឹងការលើកលែងសម្រាប់ជីកសិកម្ម។ លើសពីនេះទៀតសេចក្តីសម្រេចខាងលើក៏បានទិតៀនខ្លាំងៗពីដំណើរទស្សនកិច្ចរបស់លោកPeterSzijjartoរដ្ឋមន្ត្រីក្រសួងការបរទេសហុងគ្រីទៅកាន់ទីក្រុងមីនស្ក៍ប្រទេសបេឡារុស កាលពីខែកុម្ភៈឆ្នាំ២០២៣ដែលជាការដើរផ្ទុយទៅនឹងគោលនយោបាយរបស់សហភាពអឺរ៉ុប។ សេចក្តីសម្រេចដដែលក៏បានអំពាវនាវឱ្យដាក់សម្ពាធលើគណៈកម្មាធិការអូឡាំពិកអន្តរជាតិ ដើម្បីធានាថា អត្តពលិកមកពីប្រទេសបេឡារុសនៅតែត្រូវបានហាមឃាត់ពីការប្រកួតនៅកីឡាអូឡាំពិករដូវកាលក្រោយ ដែលនឹងធ្វើឡើងនៅក្នុងទីក្រុងប៉ារីស៕

*ព័ត៌មានសភាទូទៅអឺរ៉ុប ១៧-០៣-២៣- ឈាវ សុផាត*

ប្រែសម្រួលពី៖ https://www.macaubusiness.com/eu-parliament-urges-tougher-sanctions-on-belarus/

# EU parliament urges tougher sanctions on Belarus

The European Parliament on Wednesday urged EU countries to impose new sanctions on Belarus over its crackdown on the opposition and support for Russia's war in Ukraine.

The 27-nation bloc has already hit Minsk with multiple rounds of sanctions over its domestic repression and role as a springboard for Moscow's invasion.

Lawmakers approved a non-binding resolution calling for the EU to broaden the list of those targeted over the clampdown, in a vote that followed the sentencing of Nobel Prize winning activist Ales Bialiatski to 10 years in jail.

They said more "judges, prosecutors, and law enforcement, prison and penal colony officials" should be included on an assets freeze and visa ban blacklist.

The EU legislature also urged the bloc to tighten sanctions over Belarus' role in the war on its neighbour Ukraine to mirror sweeping punishment imposed on Russia and curb Moscow's ability to sidestep the measures.

EU officials had hoped to toughen sanctions on Belarus over the conflict in February, but the move has remained snarled over a disagreement on exemptions for fertilisers.

The resolution in addition slammed a visit by Hungarian Foreign Minister Peter Szijjarto to Minsk last month as contrary to EU policy.

It also called for pressure to be put on the International Olympic Committee to ensure that athletes from the country remain banned from competing at the next Olympic Games in Paris.

https://www.macaubusiness.com/eu-parliament-urges-tougher-sanctions-on-belarus/